| ការលះបង់របស់ចុងចោទចំពោះការជំនុំជម្រះដោយគណៈវិនិច្ឆ័យ និងសុខចិត្តទទួលការជំនុំជម្រះដោយចៅក្រម | លេខសំណុំរឿង | តុលាការវិនិច្ឆ័យទោសរដ្ឋម៉ាស្សាឈូសេត្ស<br>តុលាការជាន់ខ្ពស់ |
|---|---|---|
| រដ្ឋ v. | ខោនធី | |

## ការលះបង់របស់ចុងចោទចំពោះការជំនុំជម្រះដោយគណៈវិនិច្ឆ័យ និងសុខចិត្តទទួលការជំនុំជម្រះដោយចៅក្រម

ខ្ញុំដឹងថាខ្ញុំមានសិទ្ធិដើម្បីឱ្យមានគណៈវិនិច្ឆ័យសម្រេច ថាតើខ្ញុំជាប់ពិរុទ្ធឬអត់ ចំពោះការចោទប្រកាន់មកលើខ្ញុំ។ ខ្ញុំក៏ដឹងដែរថា ខ្ញុំមានសិទ្ធិឱ្យចៅក្រម ជំនួសគណៈវិនិច្ឆ័យ សម្រេចថាខ្ញុំជាប់ពិរុទ្ធឬអត់។

ខ្ញុំលះបង់សិទ្ធិរបស់ខ្ញុំដោយស្ម័គ្រចិត្តក្នុងទទួលការជំនុំជម្រះដោយគណៈវិនិច្ឆ័យក្នុងករណីនេះ ហើយផ្ទុយទៅវិញយល់ព្រមនឹងការជំនុំជម្រះដោយចៅក្រម។ ការសម្រេចចិត្តរបស់ខ្ញុំមិនមែនជាលទ្ធផលនៃកម្លាំង ការគំរាមកំហែង សម្ពាធ ការជានា ឬការសន្យាណាមួយឡើយ។

ខ្ញុំពេញចិត្តដែលមេធាវីរបស់ខ្ញុំបានពន្យល់ពីសិទ្ធិនិងជម្រើសរបស់ខ្ញុំយ៉ាងពេញលេញ និងពីការសម្រេចចិត្តរបស់ខ្ញុំក្នុងការលះបង់សិទ្ធិទទួលការជំនុំជម្រះក្តីដោយគណៈវិនិច្ឆ័យ និងទទួលការជំនុំជម្រះដោយចៅក្រមវិញ។ ខ្ញុំជឿថា មេធាវីរបស់ខ្ញុំបានធ្វើដើម្បីផលប្រយោជន៍ដ៏ល្អបំផុតរបស់ខ្ញុំនៅក្នុងរឿងនេះ។ ខ្ញុំដឹងថា នៅក្នុងការជំនុំជម្រះដោយគណៈវិនិច្ឆ័យ គណៈវិនិច្ឆ័យចំនួន ១២នាក់នឹងត្រូវគេជ្រើសរើសពីចំណោមសមាជិកក្នុងសហគមន៍ ថាមេធាវីរបស់ខ្ញុំនិងខ្ញុំអាចចូលរួមក្នុងការជ្រើសរើសគណៈវិនិច្ឆ័យទាំងនោះ ហើយគណៈវិនិច្ឆ័យនោះនឹងសម្រេច ថាតើរដ្ឋបានបង្ហាញពិរុទ្ធភាពលើសពីការសង្ស័យដែលសមហេតុផលតាមអង្គហេតុ និងច្បាប់ ហើយថាគណៈវិនិច្ឆ័យម្នាក់ៗ ត្រូវតែយល់ស្របលើសេចក្តីសម្រេចនោះ។ ខ្ញុំដឹងថា នៅក្នុងការជំនុំជម្រះដោយចៅក្រម ចៅក្រមតែម្នាក់គត់សម្រេច ថាតើរដ្ឋបានបង្ហាញពិរុទ្ធភាពលើសពីមន្ទិលសង្ស័យដែលសមហេតុផលក្រោមអង្គហេតុ និងច្បាប់ដែរឬទេ។

ឥឡូវនេះ ខ្ញុំមិនស្ថិតនៅក្រោមឥទ្ធិពលនៃថ្នាំញៀន ឱសថ ស្រា ឬសារធាតុផ្សេងទៀតដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ខ្ញុំក្នុងការយល់ច្បាស់ពីសិទ្ធិទទួលការជំនុំជម្រះដោយគណៈវិនិច្ឆ័យ ឬសំរេចលះបង់សិទ្ធិនោះឡើយ។

ខ្ញុំមិនជឿថា ខ្ញុំទទួលរងពីជំងឺផ្លូវចិត្ត ស្ថានភាព ឬពិការភាពណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ខ្ញុំក្នុងការស្វែងយល់ឱ្យពេញលេញពីសិទ្ធិទទួលការជំនុំជម្រះដោយគណៈវិនិច្ឆ័យ ឬការសម្រេចចិត្តលះបង់សិទ្ធិនោះឡើយ។

ឈ្មោះចុងចោទ: ______________________________

ហត្ថលេខា: ______________________________ កាលបរិច្ឆេត: ____________________

## ការបញ្ជាក់របស់មេធាវី

ខ្ញុំបានពិភាក្សាជាមួយចុងចោទនូវសិទ្ធិទទួលការជំនុំជម្រះដោយគណៈវិនិច្ឆ័យ និងជម្រើសរបស់ចុងចោទក្នុងការលះបង់សិទ្ធិនោះ ហើយសុខចិត្តទទួលការជំនុំជម្រះដោយចៅក្រម។ G. L. c. 236, § 6; Mass. R. Crim. P. 19(a). ខ្ញុំបានពន្យល់ទៅចុងចោទថា៖ គណៈវិនិច្ឆ័យជាសមាជិកក្នុងសហគមន៍។ ចុងចោទអាចចូលរួមក្នុងការជ្រើសរើសគណៈវិនិច្ឆ័យនោះបាន។ នៅក្នុងការជំនុំជម្រះក្តីដោយគណៈវិនិច្ឆ័យៗ សម្រេច ថាតើរដ្ឋបានបង្ហាញថាមានពិរុទ្ធភាពលើសពីការសង្ស័យដែលសមហេតុផលក្រោមអង្គហេតុ និងច្បាប់ ហើយគណៈវិនិច្ឆ័យទាំងអស់ត្រូវតែយល់ព្រមលើសេចក្តីសម្រេចនោះ ហើយថា នៅក្នុងការជំនុំជម្រះក្តីដោយគណៈវិនិច្ឆ័យ ចៅក្រមធ្វើសេចក្តីសម្រេចនៃច្បាប់ ណែនាំគណៈវិនិច្ឆ័យពីច្បាប់ ហើយប្រសិនបើមានសាលក្រមដែលមានពិរុទ្ធភាព ចៅក្រមនឹងជាអ្នកដាក់ទោស។ នៅពេលចុងចោទលះបង់សិទ្ធិទទួលការជំនុំជម្រះដោយគណៈវិនិច្ឆ័យ ចៅក្រមតែម្នាក់គត់នឹងសម្រេច ថាតើខាងរដ្ឋបានបង្ហាញពិរុទ្ធភាពលើសពីការសង្ស័យដែលសមហេតុផលក្រោមអង្គហេតុ និងច្បាប់ដែរឬទេ។

ខ្ញុំពេញចិត្តដែលចុងចោទបានយល់ពីការពន្យល់របស់ខ្ញុំ និងលទ្ធផលនៃការលះបង់សិទ្ធិទទួលបានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ និងទទួលការជំនុំជម្រះដោយចៅក្រម។ ខ្ញុំក៏ពេញចិត្តដែរដែលចុងចោទមិនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង គ្រឿងញៀន ឱសថ ឬសារធាតុផ្សេងទៀតដែលអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់គេក្នុងការយល់ពេញលេញពីសិទ្ធិដែលចុងចោទបានលះបង់ចោល។ ខ្ញុំមិនដឹងអំពីជំងឺផ្លូវចិត្ត ឬពិការភាពណាមួយដែលអាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់ចុងចោទក្នុងការស្វែងយល់ពីសិទ្ធិក្នុងការជំនុំជម្រះក្តីដែលចុងចោទបានបោះបង់នោះឡើង។

ចុងចោទបានចុះហត្ថលេខាលើឯកសារនេះនៅចំពោះមុខខ្ញុំ ហើយតាមដែលខ្ញុំដឹង បានធ្វើឡើងដោយសេរី តាមឆន្ទៈ ការស្ម័គ្រចិត្ត និងវាងវៃ ហើយមិនមែនជាលទ្ធផលនៃការប្រើកម្លាំង ការគំរាមកំហែង សម្ពាធ ការជានា ឬការសន្យាអ្វីឡើយ។

ហត្ថលេខាមេធាវី: ______________________________ BBO # ____________ កាលបរិច្ឆេត: __________

## ការទទួលយល់ព្រមរបស់តុលាការ

បន្ទាប់ពីសវនាការ ខ្ញុំឃើញថា ចុងចោទបានលះបង់សិទ្ធិរបស់ខ្លួនដើម្បីទទួលការជំនុំជម្រះដោយគណៈវិនិច្ឆ័យ ដោយដឹងច្បាស់លាស់តាមឆន្ទៈ ភាពវាងវៃ និងដោយស្ម័គ្រចិត្ត។ ខ្ញុំទទួលការលះបង់សិទ្ធិទទួលការជំនុំជម្រះដោយគណៈវិនិច្ឆ័យរបស់ចុងចោទ។

ចៅក្រម: ______________________________ កាលបរិច្ឆេត:: ______________________